ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ




# បទបង្ហាញ
## ស្តីពី
## វឌ្ឍនភាពការងារ បញ្ហាប្រឈមឆ្នាំ២០១៨ និងទិសដៅការងារ ឆ្នាំ២០១៩
## របស់មន្ទីរមុខងារសាធារណៈខេត្តសៀមរាប

បង្ហាញដោយ: លោក ឆួន សុខុម
ប្រធានមន្ទីរមុខងារសាធារណៈខេត្តសៀមរាប
ថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ២០១៩

# មាតិកា

I. សេចក្តីផ្តើម

II. វឌ្ឍនភាពលើការដឹកនាំ ក្នុងមន្ទីរ

III. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨

IV. បញ្ហាប្រឈម

V. ដំណោះស្រាយការងារ

VI. ទិសដៅការងារឆ្នាំ២០១៩

## I. សេចក្តីផ្តើម

ខេត្តសៀមរាបគឺជាខេត្តមួយស្ថិតនៅភាគពាយ័ព្យ នៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ ៣១៤គ.ម ពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៦ មានព្រំប្រទល់ ខាងកើតជាប់នឹងខេត្តកំពង់ធំនិងព្រះវិហារ ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ ខាងជើងជាប់នឹងខេត្តឧត្តរមានជ័យនិងព្រះវិហារ ខាងត្បូងជាប់ខេត្តបាត់ដំបងនិង បឹងទន្លេសាប។ ខេត្តសៀមរាបមានផ្ទៃក្រឡាសរុបប្រមាណ ១០.២៩៩,៤៣ គម$^{២}$ ចែកចេញជា១២ក្រុង ស្រុក ក្នុងនោះ ១ក្រុងមាន ១៣សង្កាត់ និង១១ស្រុក មាន ៨៧ឃុំ ភូមិសរុបចំនួន៨៧៦ភូមិ ។ ចំនួនប្រជាជន 1,078,075 នាក់។ ស្មើនឹង ២២៤.៩៩៥គ្រួសារ ដង់ស៊ីតេប្រជាជន១០៥នាក់/Km$^2$ ។ គិតត្រឹមបំណាច់ឆ្នាំ ២០១៨ មន្ត្រីរាជការស៊ីវិលទូទាំងខេត្តមានចំនួនសរុប ១០,៦៧១ នាក់ ស្មើនឹង ០.៩៨% បើធៀបនឹងចំនួនប្រជាជនសរុបទូទាំងខេត្ត។

ដោយឡែកមន្ទីរមុខងារសាធារណៈខេត្តសៀមរាប មានមន្ត្រីរាជការចំនួន២៥ នាក់ និងមន្ត្រីជាប់កិច្ចសន្យាចំនួន០៥ នាក់។


Oddar Meanchey
Banteay
Meanchey
Preah Vihear
Srei Snam
Varin
Kralanh
Angkor Chum
Banteay Srey
Svay Leu
Angkor Thom
Pouk
Siem Reap
Prasat Bakong
Soutr Nikom
Chi Kraeng
Battambang
Kampong Thom
Pursat

## ក- ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

### - ចំនួនមន្ត្រីរាជការស៊ីវិលតាមខែនីមួយៗ នៃខេត្តសៀមរាប ឆ្នាំ២០១៨

| ចំនួនមន្ត្រីរាជការស៊ីវិល ឆ្នាំ២០១៨ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| **10,118** | **10,410** | **10,433** | **10,417** | **10,429** | **10,434** | **10,423** | **10,401** | **10,401** | **10,392** | **10,379** | **10,671** |



# ខ- ចំនួនមន្ត្រីរាជការតាមរដ្ឋបាលខេត្ត ក្រុង-ស្រុក និងមន្ទីរ-អង្គភាព គិតជាភាគ %



## គ- ភាគរយមន្ត្រីរាជការស៊ីវិល ធៀបនឹងចំនួនប្រជាជនក្នុងខេត្ត ឆ្នាំ២០១៨



## II. វឌ្ឍនភាពលើការដឹកនាំក្នុងមន្ទីរ

### ក-ការអនុវត្តតួនាទី ភារកិច្ចរបស់មន្ទីរ

ក្នុងឆ្នាំ២០១៨ មន្ទីរមុខងារសាធារណៈខេត្តសៀមរាប បានបំពេញបេសកកម្មរបស់ខ្លួនស្របតាមប្រកាសលេខៈ១៩៧៩ មស.នក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរមុខងារសាធារណៈរាជធានី-ខេត្ត ព្រមទាំងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន តាមរយៈនេះ មន្ទីរបានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ដោយទទួលបាននូវបទពិសោធន៍និងចំណុចវិជ្ជមានមួយចំនួនគួរឱ្យគត់សម្គាល់ដូចខាងក្រោម៖

### ក.១-ការខារដ្ឋបាល និងហិរញ្ញវត្ថុ

- បានដឹកនាំ គ្រប់គ្រង ចាត់ចែង ត្រួតពិនិត្យ និងវាយតម្លៃការងារទូទៅក្នុងក្របខ័ណ្ឌមន្ទីរ
- បានសម្របសម្រួលនិងសហការយ៉ាងជិតស្និតទាក់ទងនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ជាមួយក្រុមប្រឹក្សា គណៈអភិបាលខេត្ត មន្ទីរ-អង្គភាព និងរដ្ឋបាលក្រុង-ស្រុក
- បានសម្របសម្រួលការងារជាមួយថ្នាក់ដឹកនាំអង្គភាពជុំនាញរបស់ក្រសួងមុខងារសាធារណៈ
- គ្រប់គ្រងចំណូល-ចំណាយនិងសារពើភ័ណ្ឌរបស់មន្ទីរ
- ការគ្រប់គ្រង ការបែងចែក សារាចរលិខិត ចេញ ចូល

- បានធ្វើរបាយការណ៍ ផែនការការងារ និងគម្រោងនានារបស់មន្ទីរ
- បានសម្របសម្រួលការរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងការងារសម្រាប់សន្និបាតនៅថ្នាក់ខេត្ត
- ការគ្រប់គ្រងបុគ្គលិក ការងារស្នើសុំប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
- ការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងការងារលទ្ធកម្មសាធារណៈ ការរៀបចំរបាយការណ៍គ្រប់គ្រងថវិកាប្រចាំឆ្នាំ
- ការគ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យរបស់មន្ទីរ
- បានសម្របសម្រួល និងផ្តល់យោបល់លើកិច្ចការវិវាទមុខងារសាធារណៈ

## ក.២-ការងារគ្រួតពិនិត្យរដ្ឋបាល និងបៀវត្ស

- បានសម្របសម្រួលជាមួយអង្គភាពជុំនាញ របស់ក្រសួងមុខងារសាធារណៈ ដើម្បីទទួលតារាងបៀវត្សប្រចាំខែ និងប្រគល់តារាងបៀវត្សជូនដល់រដ្ឋបាល ខេត្ត ក្រុង-ស្រុក និងមន្ទីរ-អង្គភាពនានាជុំវិញខេត្ត
- បានសហការ សម្របសម្រួលការងារជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពរតនាគារបានល្អប្រសើរ ពាក់ព័ន្ធនឹងការបើកផ្តល់ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការ និងក្រុមប្រឹក្សា
- បានបូកសរុប និងធ្វើរបាយការណ៍លើការចំណាយឥណទានបៀវត្សប្រចាំឆ្នាំរបស់មន្ទីរ
- បានពិនិត្យ និងផ្តល់យោបល់ពីការប្រើប្រាស់ថវិកាបៀវត្សមន្ត្រីរាជការថ្នាក់ក្រោមជាតិ
- បានបង្កើតយន្តការតាមដានការបើកប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងប្រាក់ឧបត្ថម្ភប្រចាំខែរបស់ក្រុមប្រឹក្សា
- បានពិនិត្យលើសំណើរសុំប្រែប្រួលស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិល បានទៀងទាត់ និងប្រចាំខែនីមួយៗ

## ក.៣-ការងារក្របខ័ណ្ឌ និងបណ្តុះបណ្តាល

- បានស្នើសុំគោលការណ៍ពីគណៈអភិបាលខេត្ត ដើម្បីបើកវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយសិក្ខាសាលា ដល់មន្ត្រីរាជការស៊ីវិល ក្រុមប្រឹក្សា គរុសិស្ស និងមន្ត្រីជាប់កិច្ចសន្យា
- បានសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា ក្នុងការចុះពិនិត្យគ្រូបង្រៀនជាប់កិច្ចសន្យាចំណេះទូទៅ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធតាមបណ្តាក្រុង-ស្រុក
- បានស្នើសុំគោលការណ៍ពីគណៈអភិបាលខេត្ត ដើម្បីពិនិត្យស្ថានភាពទូទៅមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាតាមបណ្តាមន្ទីរ-អង្គភាព និងរដ្ឋបាលក្រុង-ស្រុក
- បានចូលរួមពិនិត្យលើពាក្យស្នើសុំប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតបឋម
- បានចូលរួមជាសមាជិក ក្នុងគណៈកម្មការត្រួតពិនិត្យការប្រឡងជ្រើសរើសគ្រូបង្រៀនកម្រិតបឋមភូមិភាគសៀមរាប
- បានធ្វើការបូកសរុបសំណើសុំប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាទូទាំងខេត្ត និងបានបញ្ជូនទៅក្រសួងមុខងារសាធារណៈដើម្បីស្នើសុំទិដ្ឋាការ សម្រាប់ប្រើប្រាស់ក្នុង ឆ្នាំ២០១៨
- បានបើកវគ្គបណ្តុះបណ្តាលការងាររដ្ឋបាល ជូនដល់មន្ត្រីជាប់កិច្ចសន្យាដែលកំពុងបំពេញការងារតាម រដ្ឋបាលខេត្ត ក្រុង-ស្រុក និងមន្ទីរ-អង្គភាព

## III. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨

### ១.ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាសទី១ និងឆមាសទី១ និងឆ្នាំ ជូនក្រសួងមុខងារសាធារណៈនិង សាលាខេត្ត
- ត្រួតពិនិត្យវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
- ការគ្រប់គ្រង និងការបែងចែកសម្ភារបរិក្ខា របស់មន្ទីរបានល្អប្រសើរ
- បានរៀបចំសំណើសុំប្រាក់បៀវត្សប្រចាំខែ សម្រាប់បើកផ្តល់ជូនមន្ត្រីរាជការរបស់មន្ទីរមុខងារសាធារណៈខេត្ត
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងប្រចាំខែរបស់មន្ទីរបានទៀងទាត់
- ធ្វើរបាយការណ៍ចំណូល ចំណាយប្រចាំឆ្នាំ២០១៨
- រៀបចំឯកសារទូទាត់ថវិការដ្ឋទេយ្យបុរេប្រទានឆ្នាំ២០១៨
- រៀបចំគម្រោងកម្មវិធីថវិកាឆ្នាំ២០១៨
- ចូលរួមវេទិការពិគ្រោះយោបល់របស់ក្រុមប្រឹក្សា ខេត្ត ក្រុង ស្រុក បានចំនួន១២ លើក
- ចូលរួមវេទិការសាធារណៈរបស់ក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋានខេត្តសៀមរាបបានចំនួន០៣ លើក

- បានទទួលគណៈប្រតិភូអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ







- បានទទួលគណៈប្រតិភូអធិការកិច្ចក្រសួងមុខងារសាធារណៈ





- បានទទួលគណៈប្រតិភូអធិការកិច្ចរបស់ក្រសួងទំនង់ទងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- បានចូលរួមប្រជុំលក្ខណៈអន្តរជាតិ០៤ លើក
- បានទទួលលិខិតចូលចំនួន ២.៣៩៥ ច្បាប់
- បានបញ្ជូនលិខិតចេញចំនួន១.៥៤១ ច្បាប់។
- ការគ្រប់គ្រង និងចុះកំណត់សំគាល់ ចលនទ្រព្យ និងអចលនទ្រព្យ របស់មន្ទីរ
- ការគ្រប់គ្រងបុគ្គលិក រក្សាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងមន្ទីរបានល្អ
- ការគ្រប់គ្រងថវិកាប្រចាំឆ្នាំបានល្អប្រសើរ
- បានរៀបចំឯកសណ្ឋាន សម្រាប់មន្ត្រីរាជការរបស់មន្ទីរ
- សកម្មភាពថ្នាក់ដឹកនាំ មន្ត្រី មន្ទីរបានចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងសកម្មភាពសំខាន់ៗ ក្នុងខេត្ត និងក្រៅខេត្ត ក្នុងឆ្នាំ២០១៨ សរុបដូចខាងក្រោម៖

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ០១ | សកម្មភាពក្នុងខេត្ត | ១៥៧ លើក |
| ០២ | សកម្មភាពក្រៅខេត្ត | ៤៥  លើក |
| សរុប | | ២០២ លើក |

## ២.ការងាររត្រួតពិនិត្យរដ្ឋបាល និងបៀវត្ស

- បែងចែកតារាងបៀវត្សប្រចាំខែរបស់មន្ត្រីរាជការជូនដល់រដ្ឋបាលខេត្ត ក្រុង-ស្រុក និងមន្ទីរ-អង្គភាព បានទាន់ពេលវេលា
- បានពិនិត្យនិងផ្តល់ទិដ្ឋាការលើសំណើសុំបេឡាបៀវត្សប្រចាំខែរបស់មន្ត្រីរាជការ និងប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា របស់មន្ទីរ-អង្គភាពជំនាញជុំវិញខេត្ត បានទាន់ពេលវេលា
- ពិនិត្យផ្ទៀងផ្ទាត់ ផ្តល់យោបល់ និងទិដ្ឋាការលើសំណើសុំនានា ពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលប្រចាំខែ នីមួយៗបានទាន់ពេលវេលា
- ពិនិត្យផ្ទៀងផ្ទាត់ ផ្តល់យោបល់ លើការរៀបចំ បង្វែរថវិកាដែលបានខុសគោលការណ៍ នៅតាមមន្ទីរ-អង្គភាព ក្នុងនោះរួមមាន៖
  - ➢ លុបឈ្មោះ ចំនួន ២២នាក់
  - ➢ មរណៈភាព ចំនួន ១០នាក់
  - ➢ បង្កប្រាក់បៀវត្ស ចំនួន ០៤នាក់
  - ➢ ទំនេរគ្មានបៀវត្ស ចំនួន ០២នាក់
  - ➢ ចូលនិវត្តន៍មុនការកំណត់ ចំនួន ០១នាក់

  សរុប៣៩នាក់ ដែលមានទឹកប្រាក់សរុប ១៨១,៣៣៦,៣០៨ រៀល ។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
មន្ទីរមុខងារសាធារណៈខេត្តសៀមរាប
លេខ: ១១៥០ អ.ស.ស

ថ្ងៃ......... ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
សៀមរាប.ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០១៨

**គោរពជូន**
**លោក ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

**កម្មវត្ថុ** ៖ ស្តីពីការបង្វែរប្រាក់បៀវត្សមន្ត្រីរាជការ ចំនួន ០៤រូប នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប ចូលថវិកាជាតិវិញ ។

**យោង** ៖
- ប្រកាសលេខ ៤១៤ អយក.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការលុបឈ្មោះបុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។
- ប្រកាសលេខ ៥៥៤ អយក.ប្រក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការលុបឈ្មោះបុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។
- ប្រកាសលេខ ៥៦៦ អយក.ប្រក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការលុបឈ្មោះបុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា
- របាយការណ៍លេខ ១៦៤៤ អយកខ.បលប ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ស្តីពីការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិលរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូនលោក ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត មេត្តាជ្រាបថា៖ ដោយផ្អែកតាមប្រកាសដូចបានចុះយោងខាងលើ មន្ត្រីរាជការ ចំនួន ០៤រូប នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ត្រូវបានក្រសួងអប់រំ យុវជន និងកីឡា ប្រកាសលុបឈ្មោះចេញពីក្របខ័ណ្ឌរដ្ឋជាស្ថាពរ ។

ជាក់ស្តែង សំណើសុំបេឡាបៀវត្សប្រចាំខែរបស់មន្ទីរ មានរាប់បញ្ចូលទាំងបៀវត្សប្រចាំខែរបស់មន្ត្រីរាជការ ចំនួន ០៤រូប ដូចមានរាយនាមខាងក្រោម ស្របតាមទឹកប្រាក់សរុបក្នុងតារាងបៀវត្សប្រចាំខែ។ ក្នុងន័យនេះ ដើម្បីអនុវត្តស្របតាមច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ ក៏ដូចជាបញ្ចៀសបាននូវការខ្ជះខ្ជាយការប្រើប្រាស់ថវិកាជាតិ ខ្ញុំសូមលោកប្រធានមន្ទីរណែនាំដល់មន្ត្រីជំនាញចាត់ចែងបង្វែរថវិកាទាំងនោះចូលថវិកាជាតិវិញ តាមរយៈរតនាគារខេត្ត ក្នុងនោះរួមមាន៖

១-លោក ប្រាក់ ព្រហស្បតិ៍សោល អត្តលេខ 1901200036 (កាលបរិច្ឆេទលុប ០១-០២-២០១៨)
-បៀវត្សខែ កុម្ភៈ ឆ្នាំ២០១៨ ចំនួន ១,១១៦,០៤០ រៀល
-បៀវត្សខែ មីនា ឆ្នាំ២០១៨ ចំនួន ១,១១៦,០៤០ រៀល
-បៀវត្សខែ មេសា ឆ្នាំ២០១៨ ចំនួន ១,២៦៥,២៣៨ រៀល
-បៀវត្សខែ ឧសភា ឆ្នាំ២០១៨ ចំនួន ១,២៦៥,២៣៨ រៀល
-បៀវត្សខែ មិថុនា ឆ្នាំ២០១៨ ចំនួន ១,២៦៥,២៣៨ រៀល
-បៀវត្សខែ កក្កដា ឆ្នាំ២០១៨ ចំនួន ១,២៦៥,២៣៨ រៀល
-បៀវត្សខែ សីហា ឆ្នាំ២០១៨ ចំនួន ១,២៦៥,២៣៨ រៀល
សរុប = ៨,៥៥៨,២៧០ រៀល



២-លោក ជឿន ប៊ុនថា អត្តលេខ 1741700160 (កាលបរិច្ឆេទលុប ០១-០១-២០១៨)
-បៀវត្សខែ មករា ឆ្នាំ២០១៨ ចំនួន ១,០៥៤,៩២០ រៀល
-បៀវត្សខែ កុម្ភៈ ឆ្នាំ២០១៨ ចំនួន ១,០៥៤,៩២០ រៀល
-បៀវត្សខែ មីនា ឆ្នាំ២០១៨ ចំនួន ១,០៥៤,៩២០ រៀល
-បៀវត្សខែ មេសា ឆ្នាំ២០១៨ ចំនួន ១,២០៤,៩២០ រៀល
-បៀវត្សខែ ឧសភា ឆ្នាំ២០១៨ ចំនួន ១,២០៤,៩២០ រៀល
-បៀវត្សខែ មិថុនា ឆ្នាំ២០១៨ ចំនួន ១,២០៤,៩២០ រៀល
-បៀវត្សខែ កក្កដា ឆ្នាំ២០១៨ ចំនួន ១,២០៤,៩២០ រៀល
-បៀវត្សខែ សីហា ឆ្នាំ២០១៨ ចំនួន ១,២០៤,៩២០ រៀល
សរុប = ៩,១៨៩,៣៦០ រៀល

៣-លោក ខូ សុភីន អត្តលេខ 1731700195 (កាលបរិច្ឆេទលុប ០១-០៣-២០១៨)
-បៀវត្សខែ មីនា ឆ្នាំ២០១៨ ចំនួន ១,១៦៤,៩២០ រៀល
-បៀវត្សខែ មេសា ឆ្នាំ២០១៨ ចំនួន ១,៣១៤,៩២០ រៀល
-បៀវត្សខែ ឧសភា ឆ្នាំ២០១៨ ចំនួន ១,២៦៤,៩២០ រៀល
-បៀវត្សខែ មិថុនា ឆ្នាំ២០១៨ ចំនួន ១,២៦៤,៩២០ រៀល
-បៀវត្សខែ កក្កដា ឆ្នាំ២០១៨ ចំនួន ១,២៦៤,៩២០ រៀល
-បៀវត្សខែ សីហា ឆ្នាំ២០១៨ ចំនួន ១,២៦៤,៩២០ រៀល
សរុប = ៧,៥៣៩,៥២០ រៀល

៤-លោក អ៊ា ឆេងលីវ អត្តលេខ 1731700195 (កាលបរិច្ឆេទលុប ០១-០៤-២០១៨)
-បៀវត្សខែ មេសា ឆ្នាំ២០១៨ ចំនួន ១,៤៧៧,៥៤០ រៀល
-បៀវត្សខែ ឧសភា ឆ្នាំ២០១៨ ចំនួន ១,៤៧៧,៥៤០ រៀល
-បៀវត្សខែ មិថុនា ឆ្នាំ២០១៨ ចំនួន ១,៤៧៧,៥៤០ រៀល
-បៀវត្សខែ កក្កដា ឆ្នាំ២០១៨ ចំនួន ១,៤៧៧,៥៤០ រៀល
-បៀវត្សខែ សីហា ឆ្នាំ២០១៨ ចំនួន ១,៤៧៧,៥៤០ រៀល
សរុប = ៧,៣៨៧,៧០០ រៀល

សរុបរួម = ៣២,៦៧៤,៨៥០ រៀលគត់

ន័យដូចបានជម្រាបជូនខាងលើ សូម លោក ប្រធាន មេត្តាជ្រាប និងចាត់ចែងចំពោះករណីខាងលើនេះតាមការគួរ។

សូម លោក ប្រធាន មេត្តាទទួលនូវសេចក្តីគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**ប្រធានមន្ទីរ**

**នួន សុខុម**

<u>ចម្លងជូន៖</u>
-ក្រសួងមុខងារសាធារណៈ
-ក្រុមប្រឹក្សាខេត្ត
-គណៈអភិបាលខេត្ត
*"ដើម្បីគោរពជូនជ្រាប"*
-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
-រតនាគារខេត្ត
*"ដើម្បីជូនជ្រាប និងសហការ"*
ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប
លេខ.....១៣៤/០១៨........

| |
|---|
| លេខកូដ ៖...................... |
| ឥណពន្ធ ៖...................... |
| ឥណទាន ៖...................... |

## សលាកបត្របង់សំណែសចំណាយ(ក្នុងឆ្នាំ)

-ឈ្មោះនិងអាសយដ្ឋានអង្គភាពបង់សំណែសចំណាយ ៖ សាលាដំបូងខេត្តសៀមរាប

-ឈ្មោះនិងអាសយដ្ឋានអង្គភាពជាម្ចាស់គ្រប់គ្រង ៖ ក្រសួងយុត្តិធម៌

-ស្នើរតនាគារខេត្ត កត់ត្រាបន្ថយទឹកប្រាក់ចំណាយថវិកានៅក្នុងជំពូក គណនី អនុគណនី ដូចខាងក្រោម ៖

| ល.រ | អត្ថន័យនៃការបង់ប្រាក់ | ជំពូក | គណនី | អនុគណនី | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | បង់សំណែសចំណាយបៀវត្សមន្ត្រីរាជការដែលមរណភាព ក្នុងខែ ធ្នូ ឆ្នាំ២០១៧ ចំនួន១នាក់គឺលោក អ៊ុយ សំភារ និងមន្ត្រីសុំលាឈប់ពីការងារក្នុងខែ មេសា ឆ្នាំ២០១៨ ចំនួន១នាក់គឺលោក ស៊ិត ជារាម។ | | | | | |
| ១ | បៀវត្សមូលដ្ឋាន | 64 | 6402 | 64021 | 4,070,650 | |
| ២ | ប្រាក់បំណាច់មុខងារ | 64 | 6402 | 64022 | 16,780,000 | |
| ៣ | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | 64 | 6406 | 64061 | 40,000 | |
| ៤ | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 64 | 6406 | 64063 | 90,000 | |
| ៥ | បន្ទុកបុគ្គលិកផ្សេងៗទៀត | 64 | 6498 | 64981 | 0 | |
| | សរុប | | | | 20,980,650 | |

ចំនួនទឹកប្រាក់សរសេរជាអក្សរ ៖ (ម្ភៃលានប្រាំបួនរយប៉ែតសិបពាន់ប្រាំមួយរយហាសិបរៀលគត់)

ថ្ងៃ.....................ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ថ្ងៃ......៨កើត..ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រតនាគារខេត្ត ថ្ងៃទី ខែ ឆ្នាំ២០១៨ សៀមរាប ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៨

ប្រធានរតនាគារ អ្នកពិនិត្យ គណនេយ្យករ ប្រធានសាលាដំបូង ប្រធានលេខា.រដ្ឋបាល ប្រធានគណនេយ្យ

ខួន ណារ៉ា យិន_ស្រ៊ាង ប៉ែន [illegible]

---

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡា
ខេត្ត សៀមរាប
លេខ: ២៣៣៧ អយកខ.គន

| |
|---|
| លេខកូដ ៖ ១៦-៩-១៧ |
| ឥណពន្ធ ៖ ១១០៥១ |
| ឥណទាន ៖ ៦៤ |

## សាលាកប័ត្របង់សំណែសចំណាយ (ក្នុងឆ្នាំ)

- ឈ្មោះនិងអាស័យដ្ឋានអង្គភាពបង់សំណេះសំណាយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត

- ឈ្មោះនិងអាស័យដ្ឋានអង្គភាពជាម្ចាស់គ្រប់គ្រង ៖ ក្រសួងអប់រំ យុវជន និងកីឡា

- ស្នើរតនាគារខេត្ត កត់ត្រាបន្ថយទឹកប្រាក់ចំណាយថវិកានៅក្នុងជំពូក គណនី អនុគណនី ដូចខាងក្រោមៈ

| ល.រ | អត្ថន័យនៃការបង់ប្រាក់ | ជំពូក | គណនី | អនុគណនី | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| - | ប្រាក់បៀវត្ស មូលដ្ឋាន | 64 | 6402 | 64021 | 32,464,349 | |
| - | ប្រាក់បំណាច់មុខងារ | 64 | 6402 | 64022 | 23,200,000 | |
| - | ប្រាក់បំប៉នជីវភាពពិសេស | 64 | 6402 | 64025 | 880,000 | |
| - | កូនមានអាយុចាប់ពី២០ឆ្នាំចុះ | 64 | 6406 | 64061 | 380,000 | |
| - | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 64 | 6406 | 64063 | 180,000 | |
| | សរុប | | | | 57,104,349 | |

ចំនួនទឹកប្រាក់សរសេរជាអក្សរៈ ហាសិបប្រាំពីរលាន មួយរយបួនពាន់ បីរយសែសិបប្រាំបួនរៀលគត់

រតនាគារខេត្ត ,ថ្ងៃទី...26...ខែ.....12...ឆ្នាំ២០១៨ ធ្វើនៅ,ថ្ងៃទី...២៦....ខែ...ធ្នូ....ឆ្នាំ២០១៨

ប្រធានរតនាគារ អ្នកពិនិត្យ គណនេយ្យករ ប្រធានអង្គភាព ប្រធានគណនេយ្យ

សោម តារា

សេង ភុក ឈាង_ចាន់ឡេក សយ និត្យាវង្ស ស៊ិត_គុណឌី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត សៀមរាប

លេខ:....១៤៧/...ម.អ.ជ /១៦

សៀមរាប,ថ្ងៃទី ..០២. ខែ កញ្ញា ឆ្នាំ ២០១៦

## សាលាកប័ត្របង់ប្រាក់សំណោះចំណាយ ដោយសាច់ប្រាក់

| |
|---|
| លេខកូដ: ២០.៩.១៧ |
| ឥណពន្ធ: |
| ឥណទាន: |

ឈ្មោះអង្គភាពដែលត្រូវបង់ប្រាក់ចូលថវិការដ្ឋ: មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តសៀមរាប

ឈ្មោះអង្គភាពម្ចាស់គ្រប់គ្រង: ក្រសួងអភិវឌ្ឍន៍ជនបទ

បង់ចូលថវិការដ្ឋ: បៀវត្សប្រចាំ ខែ មិថុនា និង ខែ កក្កដា ឆ្នាំ ២០១៦

| អត្ថន័យចំណាយ | អនុគណនី | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|
| បៀវត្សមូលដ្ឋាន | ៦៤០២១ | ៩០១.០០០ ៛០០ | បៀវត្ស លោក ជា កែ |
| ប្រាក់បំណាច់មុខងារ | ៦៤០២២ | ៥០០.០០០ ៛០០ | ប្រចាំ ខែ មិថុនា និង ខែ កក្កដា |
| ប្រាក់ឧបត្ថម្ភកូន | ៦៤០៦១ | ១០.០០០ ៛០០ | |
| ប្រាក់ឧបត្ថម្ភប្រពន្ធ | ៦៤០៦៣ | ១២.០០០ ៛០០ | |
| ទឹកប្រាក់សរុប ÷ | | ១.៤២៣.០០០ ៛០០ | |

បញ្ឈប់ត្រឹមទឹកប្រាក់សរសេរជាអក្សរ : ( មួយលាន បួនរយម្ភៃបីពាន់រៀលគត់ ) ។

សៀមរាប, ថ្ងៃទី..០២...ខែ..០៩.. ឆ្នាំ ២០១៦

សៀមរាប, ថ្ងៃទី..០២...ខែ..កញ្ញា.. ឆ្នាំ ២០១៦

ប្រធានធនាគារខេត្ត អ្នកពិនិត្យ គណនេយ្យករ ប្រធានអង្គភាព ប្រធានគណនេយ្យ និងហិរញ្ញវត្ថុ

សេង ភុក ឈាង ចាន់ឡេក សោម ពាក ស៊ុំ រដ្ឋា រាជ ស្រីមុំ

---

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡា

ខេត្ត សៀមរាប

លេខ: ៤៣៣៣ ....អយកខ.គន

| |
|---|
| លេខកូដ ៖ ១៦-៩-១៧ |
| ឥណពន្ធ ៖ ៤៧០៥ |
| ឥណទាន ៖ ៧៦ |

## សាលាកប័ត្របង់ចំណូលចូលថវិកាជាតិ ដោយបង្វែរ

- ឈ្មោះនិងអាស័យដ្ឋានអង្គភាពបង់សំណោះសំណាយ៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- ឈ្មោះនិងអាស័យដ្ឋានអង្គភាពជាម្ចាស់គ្រប់គ្រង ៖ ក្រសួងអប់រំ យុវជន និងកីឡា
- ស្នើរតនាគារខេត្ត កត់ត្រាជាចំណូលថវិកានៅក្នុងជំពូក គណនី អនុគណនី ដូចខាងក្រោម:

| ល.រ | អត្ថន័យនៃការបង់ប្រាក់ | ជំពូក | គណនី | អនុគណនី | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | ចំណូលផលហិរញ្ញវត្ថុផ្សេងទៀត | 76 | 7698 | 76981 | 33,923,750 | (បុគ្គលិក ព្យួរបៀវត្ស និង លុបឈ្មោះចេញពីក្របខ័ណ្ឌ ឆ្នាំ២០១៦ និង ២០១៧)។ |
| សរុប | | | | | 33,923,750 | |

ចំនួនទឹកប្រាក់សរសេរជាអក្សរៈ សាមសិបបីលាន ប្រាំបួនរយម្ភៃបីពាន់ ប្រាំពីររយហាសិបរៀលគត់

រតនាគារខេត្ត ,ថ្ងៃទី ..០១...ខែ..៩......ឆ្នាំ២០១៨

ធ្វើនៅ,ថ្ងៃទី...២៦.....ខែ...ធ្នូ...ឆ្នាំ២០១៨

ប្រធានធនាគារ អ្នកពិនិត្យ គណនេយ្យករ ប្រធានអង្គភាព ប្រធានគណនេយ្យ

សេង ភុក ឈាង ចាន់ឡេក គល់ សម្ផាត សយ ឧត្តរាវង្ស

ស៊ីត់ គុណាឌី

# ការបង់សំណៃសចំណាយប្រាក់បៀវត្សបើកខុសគោលការណ៍ តាមធនាគារ


ACLEDA Bank Plc.

Withdrawal / Top Up / Transfer / Loan Repayment

Please fill in the information below

Account number: 3495-01-566001-11

Account name

Amount in figure: R 1,790,795

Amount in words

Transfer to account/Mobile phone No.

Account name

Fee:

Total amount:

Own account / Third party account / ACLEDA Unity / ACLEDA Unity ToanChet / Other

FOR BANK USE ONLY

Prepared by: 25.12.18

Approved by

Denomination

Receiver's signature

Account holder or depositor's signature

Please check your transaction before leaving the counter

CUSTOMER'S COPY

Form C-M

1,790,795

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**
**ACLEDA Bank Plc.**

☐ ដាក់ប្រាក់ / Deposit ☐ ទូទាត់វិក្កយបត្រ / Bill Payment
TT18204Y7 ☐ ដកប្រាក់ / Withdrawal ☐ ទិញកាតទូរស័ព្ទ / Top Up
☑ ផ្ទេរប្រាក់ / Transfer ☐ សំណងឥណទាន / Loan Repayment

សូមបំពេញព័ត៌មានខាងក្រោម/ Please fill in the information below

| | | | |
|---|---|---|---|
| លេខគណនី Account number | 3475-01643477-18 | ផ្ទេរចូលគណនី/ទូរស័ព្ទលេខ Transfer to account/Mobile phone No. | 3475-01566001-11 |
| ឈ្មោះគណនី Account name | [illegible] | ឈ្មោះគណនី Account name | [illegible] |
| ចំនួនជាលេខ Amount in figure | KH 12,145,009.00 | កម្រៃសេវា/Fee: | ចំនួនទឹកប្រាក់សរុប/Total amount: 12,145,009.00 |
| ចំនួនជាអក្សរ Amount in words | [illegible] | ☐ គណនីផ្ទាល់/Own account ☐ គណនីភាគីទីបី/Third party account ☐ អេស៊ីលីដាយូនីធី/ACLEDA Unity ☐ អេស៊ីលីដាយូនីធីទាន់ចិត្ត/ACLEDA Unity ToanChet ☐ ផ្សេងៗ/Other | |

DR A/C 3475-01-643477-1-8 Payment Agent Account-SRP Health
CR A/C 3475-01-586001-1-1 Current Account for Revenue
Amt Tr. KHR 12,145,009.00
Fee Collection KHR 0.00
23/07/18

Narrative TT CR

| សម្រាប់ធនាគារ/FOR BANK USE ONLY | |
|---|---|
| Prepared by | Approved by |
| ABC.11788 | |

Denomination

ហត្ថលេខាអ្នកទទួលប្រាក់
Receiver's signature

ហត្ថលេខាម្ចាស់គណនី ឬអ្នកដាក់ប្រាក់បញ្ញើ
Account holder or depositor's signature

CUSTOMER'S COPY

Form C-

សូមពិនិត្យប្រតិបត្តិការរបស់អ្នកមុននឹងចាកចេញពីបញ្ជរ/Please check your transaction before leaving the counter




- ពិនិត្យផ្ទៀងផ្ទាត់ ផ្តល់យោបល់ និងផ្តល់នីត្យានុកូលភាពលើដីកា សម្រេចបាន៣៣ដីកា ស្មើនឹង ១៣៩នាក់ ក្នុងនោះរួមមាន៖

-ការតែងតាំង ចំនួន ៧០ នាក់

-ការប្រគល់ភារកិច្ច ចំនួន ៥៦ នាក់

-ការបញ្ចប់មុខតំណែង ចំនួន ០១ នាក់

-ផ្លាស់ប្តូរកន្លែងបម្រើការងារ ចំនួន ០២ នាក់

-ផ្លាសប្តូរភារកិច្ច ចំនួន ០៩ នាក់

-សម្រួលភារកិច្ច ឬដកមុខតំណែង ០១ នាក់

**ដែលបានឆ្លើយតបនិងដីកា សរុបចំនួន ០៦ លិខិត**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តសៀមរាប**
លេខ: ០៣៨៤/[illegible] ១៨

# ដីកា
## ស្តីពី
## ការតែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ

## អភិបាល នៃគណៈអភិបាលខេត្តសៀមរាប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិកថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៤/៦៥៤ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តសៀមរាប អាណត្តិទី២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៥៩៤ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តសៀមរាប សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌឋានន្តរសក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឲ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ
- យោងសេចក្តីណែនាំលេខ ៣៧៦៧ អយក.សណន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីមុខងារ ភារកិច្ច នៃរចនាសម្ព័ន្ធរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង
- យោងសេចក្តីណែនាំលេខ ៧៨៨ មស.សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ ស្តីពីគោលការណ៍ និងនីតិវិធី នៃការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ
- យោងសេចក្តីណែនាំលេខ ៧៨៩ មស.សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ ស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងសំណើលេខ ០៥១ សបគ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ របស់រដ្ឋបាលស្រុកប្រាសាទបាគង
- យោងស្មារតីកិច្ចប្រជុំគណៈអភិបាលខេត្ត ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ។



## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន **០៦រូប** នៅក្នុងរចនាសម្ព័ន្ធការិយាល័យអប់រំ យុវជន និងកីឡាស្រុកប្រាសាទបាគង នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ៖

១-លោក **ប៊ូញ តេ** អត្តលេខ ១៧២០២០០៦០៣ គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៤ ជានាយករងអនុវិទ្យាល័យស្រិត

២-លោកស្រី **ទ្រាំ សុឡុន** អត្តលេខ ២៨០១៧០០០៥២ គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ២ ជានាយិការងអនុវិទ្យាល័យហ៊ុន សែន រលួស

៣-លោកស្រី **សេខ សាម៉ន** អត្តលេខ ២៧៣១៧០០១៥២ គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៣ ជានាយិការងអនុវិទ្យាល័យស្រីវិបុលកេរ្តិ៍

៤-លោកស្រី **ស៊ិន សំ** អត្តលេខ ២៨៩១៧០០០៣៨ គ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ ៨ ជានាយិការងសាលាបឋមសិក្សាភូមិស្ទឹង

៥-លោក **ព្រែក សុផល** អត្តលេខ ១៩២១៧០០០១២ គ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ ៨ ជានាយករងសាលាបឋមសិក្សាវេស្សវ័ណ

៦-លោកស្រី **ខ្មៅ ម៉ារ៉ា** អត្តលេខ ២៧៦១៧០០០៦៨ គ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ ៨ ជានាយិការងសាលាបឋមសិក្សាកំពង់ភ្លុក

**ប្រការ២.-**

ត្រូវបានប្រគល់ភារកិច្ចមន្ត្រីរាជការចំនួន **០៦រូប** នៅក្នុងរចនាសម្ព័ន្ធការិយាល័យអប់រំ យុវជន និងកីឡាស្រុកប្រាសាទបាគង នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ៖

១-លោក **ទ៉ាន់ សារុន** អត្តលេខ ១៦៦២០០០១១៥ គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៣ ជានាយកវិទ្យាល័យស្នាតេជោ ៣១៧

២-លោក **ចាក់ គិមឈីន** អត្តលេខ ១៧២០២០០៦០៤ គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ថ្នាក់លេខ ៣ ជានាយកវិទ្យាល័យតាអី

៣-លោក **ឡឿន ឌី** អត្តលេខ ១៧៨១៧០០០៤៨ គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ ៣ ជានាយកវិទ្យាល័យកំពង់ភ្លុក

៤-លោក **ហួក សុខាន់** អត្តលេខ ១៨៥១៧០០០០៩ គ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ ៨ ជានាយកសាលាបឋមសិក្សាត្រពាំងពោធិ៍

៥-លោកស្រី **សួន សោភា** អត្តលេខ ២៨៤១៧០០១៣៦ គ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ ៨ ជានាយិកាសាលាបឋមសិក្សាកំពង់ថ្កូវ

៦-លោកស្រី **តូ រ័ត្នន៍** អត្តលេខ ២៨៥១៧០០០៥០ គ្រូបង្រៀនកម្រិតបឋម ថ្នាក់លេខ ៨ ជានាយិកាសាលាបឋមសិក្សាតាអី

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងដីកានេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៤.-

នាយករដ្ឋបាលសាលាខេត្ត ក្រុមប្រឹក្សា និងគណៈអភិបាលស្រុកប្រាសាទបាគង ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ប្រធានមន្ទីរមុខងារសាធារណៈខេត្ត ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត នាយកទីចាត់ការ ប្រធានអង្គភាពចំណុះសាលាខេត្ត អភិបាលក្រុង ស្រុក ប្រធានការិយាល័យនានាចំណុះរដ្ឋបាលស្រុកប្រាសាទបាគង និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ២ខាងលើ ត្រូវអនុវត្តដីកានេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ១២រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅខេត្តសៀមរាប ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨

**អភិបាលខេត្ត**

**ឃឹម ប៊ុនសុង**

**កន្លែងទទួល** ÷
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ក្រុមប្រឹក្សាខេត្ត
  "ដើម្បីគោរពជូនជ្រាប"
- មន្ទីរ អង្គភាពជុំវិញខេត្ត
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
**មន្ទីរមុខងារសាធារណៈខេត្តសៀមរាប**
លេខ.....៤៦៧.....ម.ស.ស.ស

ថ្ងៃព្រហស្បតិ៍ ១រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប,ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៩

## សូមគោរពជូន
## ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តសៀមរាប

**កម្មវត្ថុ** ៖ ការពិនិត្យលើដីកាស្តីពីការបញ្ចប់មុខតំណែង ការតែងតាំង ការផ្លាស់ប្តូរ និងប្រគល់ភារកិច្ចមន្ត្រីរាជការ របស់មន្ទីរ-អង្គភាព ចំនួន ០៦ ។

**យោង** ៖
- អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ។
- សេចក្តីណែនាំលេខ ៧៨៨ មស.សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីគោលការណ៍និងនីតិវិធី នៃការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ-អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ របស់ក្រសួងមុខងារសាធារណៈ។
- ដីកាលេខ ០០៣/១៩ ដក.គត ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ
- ដីកាលេខ ០០៤/១៩ ដក.គត ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ស្តីពីការផ្លាស់ប្តូរភារកិច្ច និងតែងតាំងមន្ត្រីរាជការ
- ដីកាលេខ ០០៥/១៩ ដក.គត ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ស្តីពីការបញ្ចប់មុខតំណែង តែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ
- ដីកាលេខ ០០៦/១៩ ដក.គត ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ
- ដីកាលេខ ០០៧/១៩ ដក.គត ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ស្តីពីការប្រគល់ភារកិច្ចមន្ត្រីរាជការ
- ដីកាលេខ ០០៨/១៩ ដក.គត ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ស្តីពីការតែងតាំង ផ្លាស់ប្តូរ និងប្រគល់ភារកិច្ចមន្ត្រីរាជការ
- ដីកាលេខ ០០៩/១៩ ដក.គត ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ស្តីពីការផ្លាស់ប្តូរកន្លែងបម្រើការងារមន្ត្រីរាជការ
- ដីកាអមលេខ ០៤៨/១៩ ដកអ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តសៀមរាប។

ន័យដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តម អភិបាល** នៃគណៈភិបាលខេត្ត មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់៖ មន្ទីរមុខងារសាធារណៈខេត្ត បានទទួលដីកាទាំង០៧ រួចហើយ ស្របតាមរយៈពេលមានកំណត់ក្នុងលិខិតបទដ្ឋានជាធរមាន។ មន្ទីរបានពិនិត្យលើទម្រង់និងគតិនៃដីកាទាំង០៧ ដូចបានចុះយោងខាងលើ យ៉ាងល្អិតល្អន់រួមទាំងឯកសារឧបសម្ព័ន្ធភ្ជាប់មកជាមួយនៃមន្ទីរ-អង្គភាពទាំង៦ រួមមាន៖ ១-រដ្ឋបាលខេត្ត ២-មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត ៣-មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ៤-មន្ទីរកិច្ចការនារីខេត្ត ៥-មន្ទីរសុខាភិបាលខេត្ត ៦-មន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ មន្ទីរមុខងារសាធារណៈខេត្ត សូមយល់ស្របទាំងស្រុងលើទម្រង់ និងគតិដីកាទាំង០៧ ខាងលើដោយបានអនុវត្តស្របតាមអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨។

មន្ទីរមុខងារសាធារណៈខេត្ត នឹងធ្វើការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលជូនសាមីខ្លួនដូចមានរាយនាមក្នុងដីកាខាងលើស្របតាមពេលវេលា និងនីតិវិធីជាធរមាន។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តម អភិបាល** នៃគណៈអភិបាលខេត្ត មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តម** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធានមន្ទីរ**

**នួន សុខុម**

**ចម្លងជូន:**
- ក្រសួងមុខងារសាធារណៈ
- ក្រុមប្រឹក្សាខេត្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
- រតនាគារខេត្ត
- មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត
- មន្ទីរកិច្ចការនារីខេត្ត
- មន្ទីរសុខាភិបាលខេត្ត
- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត
  "ដើម្បីគោរពជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

# ស្ថានភាពប្រែប្រួលរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិល ឆ្នាំ២០១៨



# ស្ថានភាពសហព័ន្ធមន្ត្រីរាជការ និង កូនក្នុងបន្ទុក



## ៣-ការងារក្របខ័ណ្ឌ និងបណ្តុះបណ្តាល

- បើកវគ្គផ្សព្វផ្សាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ដល់មន្ត្រីរាជការស៊ីវិល ដែលជាថ្នាក់ដឹកនាំរដ្ឋបាលខេត្ត ក្រុង-ស្រុក និងមន្ទីរ-អង្គភាព បានចំនួន០១ លើក សិក្ខាកាមសរុប ១៥១ នាក់






សិក្ខាសាលាផ្សព្វផ្សាយ
ខ្លឹមសារអនុក្រឹត្យ២៤០ អនក្រ.បក សេចក្តីណែនាំលេខ៧៨៨ មស.សណន
សេចក្តីណែនាំលេខ៧៨៩ មស.សណន និង លិខិតបទដ្ឋានគតិយុត្តិសំខាន់ៗ
ជូនមន្ត្រីរាជការស៊ីវិល
ថ្ងៃចន្ទ ១កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
សៀមរាប ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨



- បើកវគ្គប្រជុំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ដល់គរុសិស្សឆ្នាំទី២ ជំនាន់ទី៣៥ បានចំនួន០១ លើក សិក្ខាកាមសរុប ១៨០ នាក់ ហើយពេលបញ្ចប់ការវគ្គផ្សព្វផ្សាយ មន្ទីរបានចេញវិញ្ញាបនប័ត្រជូនដល់សិក្ខាកាម។






to be the best and for prosperity

- បើកវគ្គប្រជុំផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ដល់មន្ត្រីរាជការស៊ីវិលវិស័យអប់រំ ដែលជាថ្នាក់ដឹកនាំគ្រឹះស្ថានសិក្សាសាធារណៈរបស់រដ្ឋ (នាយក នាយិកា) បានចំនួន០១ លើក សិក្ខាកាមសរុប ៨៥៨ នាក់



- បានផ្សព្វផ្សាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរអភិវឌ្ឍន៍ជនខេត្ត តាមការស្នើសុំ







- បានបើកវគ្គផ្សព្វផ្សាយស្តីពីមូលដ្ឋានគ្រឹះ នៃកិច្ចការរដ្ឋបាលទូទៅ ព្រមទាំងច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈដល់មន្ត្រី ជាប់កិច្ចសន្យាបម្រើការងារនៅតាមមន្ទីរ អង្គភាព សាលាក្រុង ស្រុក បានចំនួន០៣វគ្គ ដែលមានសមាសភាព ចូលរួមសរុបចំនួន២៣៨នាក់ ស្រី១១០នាក់។





- បានធ្វើការបូកសរុបសំណើសុំប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាទូទាំងខេត្ត និងបានបញ្ជូនទៅក្រសួងមុខងារសាធារណៈដើម្បីស្នើសុំទិដ្ឋាការ សម្រាប់ប្រើប្រាស់ក្នុង ឆ្នាំ២០១៨
- បានផ្តល់ទិដ្ឋាការលើការប្រើប្រាស់គ្រូបង្រៀនអប់រំក្រៅប្រព័ន្ធ (អក្ខរកម្ម)ចំនួន១០៥នាក់។
- បោះពុម្ពតារាងទូទាត់ប្រាក់កម្រៃប្រចាំខែនីមួយៗសម្រាប់មន្ត្រីជាប់កិច្ចសន្យាទូទាំង ខេត្តបានទាន់ពេលវេលា
- ពិនិត្យផ្ទៀងផ្ទាត់លើសំណើសុំថវិកាសម្រាប់បើកផ្តល់ជូនមន្ត្រីជាប់កិច្ចសន្យា
- ពង្រឹងការគ្រប់គ្រងការប្រើប្រាស់ និងការផ្តល់ប្រាក់លាភការតាមប្រព័ន្ធធនាគារ ជូនមន្ត្រីជាប់កិច្ចសន្យា
- រៀបចំរបាយការណ៍បូកសរុប ស្តីពីលទ្ធផលសម្រេចបានក្នុងការចុះផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ តាមបណ្តាក្រុង ស្រុក និងមន្ទីរ អង្គភាពជុំនាញជុំវិញខេត្ត

- បានសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចុះពិនិត្យលើការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះទូទៅដែលមានតម្រូវការបន្ថែម ចំនួន០១ លើក ស្មើ១៧៦ នាក់ នៅតាមបណ្ដាក្រុង-ស្រុក ទូទាំងខេត្ត
- ចូលរួមសហការអន្តរក្រសួងរវាងក្រសួងមុខងារសាធារណៈ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីសមាហរណកម្មមន្ត្រីជាប់កិច្ចសន្យាអចិន្ត្រៃយ៍អង្វាធរអេប្បរា ទៅក្នុងក្របខ័ណ្ឌក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សរុបចំនួន ៣៨៣នាក់

➢ បានចុះពិនិត្យស្ថានភាពប្រើប្រាស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា តាមបណ្ដាមន្ទីរ-អង្គភាពជំនាញជុំវិញខេត្តបានចំនួន ០១លើក ជាលទ្ធផលៈ

- ប្រជុំណែនាំដោយមានកំណត់ហេតុ ចំនួន០៦ករណី ស្មើនឹងចំនួនមន្ត្រី ៨៧នាក់
- បង្អកប្រាក់បៀវត្សរយៈពេលខ្លីចំនួន០២ ករណី ស្មើនឹងចំនួនមន្ត្រី ១១នាក់
- ណែនាំឱ្យដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន០២ ករណី ស្មើនឹងចំនួនមន្ត្រី ០៧ នាក់
- លុបប្រាក់បំណាច់មុខងារចំនួន០១ ករណី ស្មើនឹងចំនួនមន្ត្រី០១ នាក់
- ស្នើឱ្យដាក់ពាក្យសុំស្ថិតនៅក្រៅអង្គភាពដើម០៣ ករណី ស្មើនឹងចំនួនមន្ត្រី០៣ នាក់

- ចុះពិនិត្យស្ថានភាពមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដែលកំពុងបម្រើការងារ នៅតាមមន្ទីរ

-អង្គភាពជំនាញជុំវិញខេត្ត និងរដ្ឋបាលក្រុង ស្រុក







TRANSPORTATION OFFICE




- កោះហៅមកប្រជុំណែនាំនៅមន្ទីរមុខងារសាធារណៈ ចំពោះគ្រូបង្រៀនកម្រិតឧត្តមនៅតាមវិទ្យាល័យក្នុងក្រុងសៀមរាប០១ ករណី ស្មើនឹងចំនួន ១១៦នាក់
- បានសហការនិងសម្របសម្រួលជាមួយមន្ទីរ-អង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យមន្ត្រីរាជការមួយចំនួនពិនិត្យស្ថានភាពទូទៅរបស់មន្ត្រីរាជការនិងគ្រូបង្រៀននៅតាមគ្រឹះស្ថានអប់រំសាធារណៈបាន០១លើក

**សកម្មភាពចុះពិនិត្យគ្រូបង្រៀនជាប់កិច្ចសន្យា ចំណេះទូទៅ**










INDEX


SPARK
1·0192

INDEX



- ចុះពិនិត្យតម្រូវការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា ផ្ទាំទ្វារទឹក នៅស្រុកជីក្រែង និងស្រីស្នំ





- បានផ្សព្វផ្សាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរអភិវឌ្ឍន៍ជនខេត្ត តាមការស្នើសុំ
- បានពិនិត្យផ្ទៀងផ្ទាត់ បញ្ចូល ផលិត និងផ្តល់ទិដ្ឋាការ តារាងប្រាក់ឧបត្ថម្ភមន្ត្រីជាប់កិច្ចសន្យារបស់មន្ទីរ-អង្គភាពជំនាញនានាជុំវិញខេត្ត និងក្រុង ស្រុក ទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យានៃការគ្រប់គ្រងបានប្រើប្រាស់ សម្រាប់បើកផ្តល់ជូន ទាន់ពេលវេលា។
- បានពិនិត្យផ្ទៀងផ្ទាត់ បញ្ចូល ផលិត និងផ្តល់ទិដ្ឋាការ តារាងប្រាក់ម៉ោងបន្ថែមរបស់លោកគ្រូអ្នកគ្រូដែលបម្រើការងារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ក្នុងខេត្តសៀមរាប បានប្រើប្រាស់ទាន់ពេលវេលា

# ការគ្រប់គ្រងមន្ត្រីរាជការតាមប្រភេទក្របខណ្ឌ "ក" "ខ" "គ"



# ចំនួនមន្ត្រីជាប់កិច្ចសន្យាតាមបណ្ដាខែ ឆ្នាំ២០១៨



## ❑ ស្ថានភាពបញ្ជ្រាបយេនឌ័រ ក្នុងវិស័យមុខងារសាធារណៈ
## ស្ថានភាពបញ្ជ្រាបយេនឌ័រ ក្នុងរចនាសម្ព័ន សាលាខេត្ត ក្រុង ស្រុក

| ក្របខ័ណ្ឌ | 525 | តួនាទី | ស្ត្រីមានតួនាទីក្នុងរចនាសម្ព័ន្ធថ្នាក់ខេត្ត | | | | | | | | ស្ត្រីមានតួនាទីក្នុងរចនាសម្ព័ន្ធថ្នាក់ក្រុង/ស្រុក | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | គណៈអភិបាល | | រដ្ឋបាល | | ទីចាត់ការ | | ការិយាល័យ | | គណៈអភិបាល | | រដ្ឋបាល | | ការិយាល័យ | |
| | | សរុប | អភិបាល | អភិបាលរង | នាយក | នាយករង | នាយក | នាយករង | ប្រធាន | អនុប្រធាន | អភិបាល | អភិបាលរង | នាយក | នាយករង | ប្រធាន | អនុប្រធាន |
| ប្រុស | 374 | 199 | 01 | 05 | 01 | 04 | 06 | 10 | 16 | 33 | 12 | 31 | 11 | 9 | 31 | 29 |
| ស្រី | 151 | 46 | 00 | 01 | 00 | 00 | 00 | 02 | 00 | 12 | 01 | 12 | 03 | 05 | 04 | 06 |
| ភាគរយស្ត្រី % | 40% | 23% | 0% | 20% | 0% | 0% | 0% | 20% | 0% | 36% | 8% | 39% | 27% | 56% | 13% | 21% |



# ស្ថានភាពបុគ្គលិកយេនឌ័រ របស់មន្ទីរ-អង្គភាពជុំវិញខេត្ត

| ល.រ | មន្ទីរ-អង្គភាព | រដ្ឋបាលខេត្ត/មន្ទីរខេត្ត | | | | ការិយាល័យមន្ទីរខេត្ត | | | | ការិយាល័យក្រុង/ស្រុក | | | | សរុបរួម | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | នាយករដ្ឋបាល / ប្រធានមន្ទីរ | | នាយករងរដ្ឋបាល / អនុប្រធានមន្ទីរ | | ប្រធាន ការិយាល័យ | | អនុប្រធាន ការិយាល័យ | | ប្រធាន ការិយាល័យ | | អនុប្រធាន ការិយាល័យ | | | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | ស្រី |
| ១ | រដ្ឋបាលខេត្ត ក្រុង ស្រុក | 1 | 0 | 4 | 0 | 16 | 0 | 33 | 12 | 31 | 4 | 29 | 6 | 114 | 22 | 19.30% |
| ២ | មន្ទីរទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 1 | 0 | 2 | 0 | 3 | 0 | 5 | 0 | 0 | 0 | 0 | 0 | 11 | 0 | 0.00% |
| ៣ | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 1 | 0 | 1 | 0 | 3 | 1 | 1 | 0 | 0 | 0 | 0 | 0 | 6 | 1 | 16.67% |
| ៤ | មន្ទីរព័ត៌មាន | 1 | 0 | 2 | 1 | 2 | 2 | 7 | 2 | 5 | 1 | 0 | 0 | 17 | 6 | 35.29% |
| ៥ | មន្ទីរសុខាភិបាល | 1 | 0 | 4 | 1 | 5 | 2 | 7 | 2 | 8 | 0 | 6 | 0 | 31 | 5 | 16.13% |
| ៦ | មន្ទីរឧស្សាហកម្ម និងសិប្បកម្ម | 1 | 0 | 3 | 0 | 3 | 0 | 4 | 1 | 0 | 0 | 0 | 0 | 11 | 1 | 9.09% |
| ៧ | មន្ទីរផែនការ | 1 | 0 | 3 | 1 | 4 | 0 | 5 | 3 | 10 | 1 | 7 | 3 | 30 | 8 | 26.67% |
| ៨ | មន្ទីរពាណិជ្ជកម្ម | 1 | 0 | 2 | 2 | 3 | 1 | 4 | 2 | 0 | 0 | 1 | 1 | 11 | 6 | 54.55% |
| ៩ | មន្ទីរអប់រំ យុវជន និងកីឡា | 1 | 0 | 5 | 0 | 10 | 2 | 20 | 2 | 11 | 0 | 20 | 3 | 67 | 7 | 10.45% |
| ១០ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 1 | 0 | 3 | 1 | 10 | 1 | 13 | 2 | 10 | 1 | 8 | 3 | 45 | 8 | 17.78% |
| ១១ | មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | 1 | 0 | 3 | 0 | 6 | 1 | 7 | 4 | 10 | 2 | 2 | 1 | 29 | 8 | 27.59% |
| ១២ | មន្ទីរបរិស្ថាន | 1 | 0 | 2 | 0 | 4 | 0 | 15 | 1 | 1 | 0 | 1 | 0 | 24 | 1 | 4.17% |
| ១៣ | មន្ទីរអភិវឌ្ឍន៍ជនបទ | 1 | 0 | 3 | 0 | 5 | 2 | 17 | 2 | 10 | 0 | 1 | 1 | 37 | 5 | 13.51% |
| ១៤ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 1 | 0 | 3 | 1 | 4 | 1 | 13 | 10 | 12 | 4 | 4 | 0 | 37 | 16 | 43.24% |
| ១៥ | មន្ទីរប្រៃសណីយ៍ | 1 | 0 | 3 | 1 | 3 | 1 | 2 | 1 | 2 | 1 | 0 | 0 | 11 | 4 | 36.36% |
| ១៦ | មន្ទីរធម្មការ និងសាសនា | 1 | 0 | 2 | 0 | 1 | 0 | 5 | 0 | 4 | 1 | 0 | 0 | 13 | 1 | 7.69% |
| ១៧ | មន្ទីរសាធារណការ និងដឹកជញ្ជូន | 1 | 0 | 5 | 0 | 9 | 0 | 24 | 4 | 2 | 1 | 1 | 1 | 42 | 6 | 14.29% |
| ១៨ | មន្ទីរទេសចរណ៍ | 1 | 0 | 4 | 0 | 6 | 1 | 22 | 9 | 0 | 0 | 0 | 0 | 33 | 10 | 30.30% |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៩ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ | 1 | 0 | 5 | 1 | 4 | 0 | 14 | 2 | 8 | 0 | 16 | 1 | 48 | 4 | 8.33% |
| ២០ | មន្ទីរធនធានទឹក និងឧតុនិយម | 1 | 0 | 3 | 0 | 4 | 1 | 10 | 1 | 2 | 0 | 0 | 0 | 20 | 2 | 10.00% |
| ២១ | មន្ទីរកិច្ចការនារី | 1 | 1 | 3 | 3 | 6 | 6 | 10 | 8 | 3 | 3 | 8 | 8 | 31 | 29 | 93.55% |
| ២២ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 1 | 0 | 3 | 1 | 5 | 0 | 11 | 4 | 0 | 0 | 0 | 0 | 20 | 5 | 25.00% |
| ២៣ | មន្ទីររ៉ែ និងថាមពល | 1 | 0 | 2 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 4 | 0 | 0.00% |
| ២៤ | មន្ទីរមុខងារសាធារណៈ | 1 | 0 | 2 | 0 | 3 | 0 | 3 | 0 | 0 | 0 | 0 | 0 | 9 | 0 | 0.00% |
| ២៥ | សាលាដំបូង | 1 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3 | 0 | 0.00% |
| សរុបរួម | | 25 | 1 | 74 | 13 | 120 | 22 | 252 | 72 | 129 | 19 | 104 | 28 | 704 | 155 | 22.02% |
| គិតជាភាគរយ (%) | | | 4% | | 18% | | 18% | | 29% | | 15% | | 27% | | 22% | |



## IV-បញ្ហាប្រឈមដែលបានអនុវត្តការងារ ឆ្នាំ២០១៨

- លិខិតបទដ្ឋានគតិយុត្តចំនួនមិនទាន់បានអនុវត្តបានសមស្រប និងរងចាំសេចក្តីណែនាំបន្ថែមពីថ្នាក់ជាតិ
- ខ្វះមន្ត្រីជាប់កិច្ចសន្យា
- ខ្វះមធ្យោបាយធ្វើដំណើរ ដើម្បីចុះមូលដ្ឋានត្រួតពិនិត្យស្ថានភាពមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា

## V-ដំណោះស្រាយ

- ❑ ស្នើសុំមន្ត្រីជាប់កិច្ចសន្យាបន្ថែមចំនួន ០៣នាក់
- ❑ ស្នើសុំមធ្យោបាយធ្វើដំណើរសម្រាប់ចុះបេសកកម្ម តាមបណ្តាស្រុក

## VI -ទិសដៅការងារសំខាន់ៗសម្រាប់ឆ្នាំ២០១៩

| ល.រ | សកម្មភាពសំខាន់ដែលគ្រោងអនុវត្ត | ត្រីមាស | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| ១ | ចុះពិនិត្យស្ថានភាពមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ដែលបម្រើការងារនៅមន្ទីរ-អង្គភាព ក្រុង ស្រុក | √ | √ | | |
| ២ | ចុះពិនិត្យស្ថានភាពមន្ត្រីរាជការជាគ្រូបង្រៀន គ្រូបង្រៀនជាប់កិច្ចសន្យា ដែលបម្រើការងារតាមគ្រឹះស្ថានសិក្សាសាធារណៈទូទាំងខេត្ត | | √ | √ | |
| ៣ | ផ្សព្វផ្សាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ជូនដល់គរុសិស្សនៃសាលាគរុកោសល្យខេត្ត | | √ | | |
| ៤ | ផ្សព្វផ្សាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ជូនមន្ត្រីរាជ ការដែលបម្រើការងារនៅតាម រដ្ឋបាលក្រុង ស្រុក ក្នុងខេត្តសៀមរាប | | √ | √ | |
| ៥ | ពិនិត្យផ្ទៀងផ្ទាត់ និងផ្តល់ទិដ្ឋាការលើសំណើសុំប្រែប្រួលស្ថានភាពរដ្ឋបាលមន្ត្រីរាជការ និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិល | √ | √ | √ | √ |

| ល.រ | សកម្មភាពសំខាន់ដែលគ្រោងអនុវត្ត | ត្រីមាស | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| ៦ | ពិនិត្យផ្ទៀងផ្ទាត់ និងផ្តល់ទិដ្ឋាការលើសំណើសុំតែងតាំង ប្រគល់ភារកិច្ច ផ្ទេរមន្ត្រីរាជការរបស់រដ្ឋបាលខេត្ត | √ | √ | √ | √ |
| ៧ | ពិនិត្យផ្ទៀងផ្ទាត់ បញ្ចូល ផលិត និងផ្តល់ទិដ្ឋាការ តារាងប្រាក់ឧបត្ថម្ភមន្ត្រីជាប់កិច្ចសន្យារបស់មន្ទីរ-អង្គភាពជុំវិញខេត្ត និងក្រុង ស្រុក | √ | √ | √ | √ |
| ៨ | ពិនិត្យផ្ទៀងផ្ទាត់ បញ្ចូល ផលិត និងផ្តល់ទិដ្ឋាការ តារាងប្រាក់ម៉ោងបន្ថែមរបស់លោកគ្រូ អ្នកគ្រូដែលបម្រើការងារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ | √ | √ | √ | √ |
| ៩ | ចូលរួមគណៈកម្មការប្រឡងជ្រើសរើសមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ក្នុងខេត្ត | √ | √ | √ | √ |
| ១០ | ពិនិត្យ និងផ្តល់ទិដ្ឋាការប្រចាំខែ លើសំណើប្រាក់បៀវត្សមន្ត្រីរាជការ ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សា | √ | √ | √ | √ |
| ១១ | បន្តតាមដានដើម្បីគៀគរប្រាក់បៀវត្សមន្ត្រីរាជការចំនួនដែលបានបើកខុសគោលការណ៍ច្បាប់ បង្វែរចូលថវិការជាតិវិញ | √ | √ | √ | √ |
| ១២ | ពង្រឹងការអនុវត្តវិធានការវិន័យរដ្ឋបាលចំពោះមន្ត្រីអសកម្ម | √ | √ | √ | √ |

សូមអរគុណ!